# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាធ្វើយុទ្ធនាការអប់រំសាធារណជនពីអំពើនិទណ្ឌភាពករណីឃាតកម្មលើអ្នកសារព័ត៌មាន

ដោយ សុ ជីវី

2024.10.29



*(រូបឯកសារ) អ្នកចូលរួមរំលែកមរណទុក្ខអុជធូបគោរពរូបថតសពកាសែត លោក ឃឹម សម្បូណ៍ នៅវត្តទួលទំពូង រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៨។*

អ្នកសារព័ត៌មានខ្មែរចំនួន១៥ នាក់ ដែលត្រូវឧក្រិដ្ឋជនសម្លាប់ រាប់តាំងពីឆ្នាំ១៩៩៤ រហូតមកដល់ពេលនេះ នៅតែមិនបានទទួលយុត្តិធម៌។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅថ្ងៃទី២៩ ខែតុលានេះ បញ្ជាក់ជាថ្មីទៀតថា មកដល់ពេលនេះអាជ្ញាធររដ្ឋាភិបាលខកខានមិនបានស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ដើម្បីនាំជនល្មើសមកជំនុំជម្រះ ដែលបណ្ដាលឱ្យករណីទាំងនេះមិនអាចដោះស្រាយ ហើយជនរងគ្រោះនៅតែមិនទទួលបានយុត្តិធម៌ ខណៈជនល្មើសនៅតែបន្តរួចខ្លួនពីការផ្ដន្ទាទោសចំពោះអំពើឧក្រិដ្ឋរបស់ពួកគេ។

ទាក់ទងនឹងបញ្ហានេះមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចាប់ផ្ដើមយុទ្ធនាការរយៈពេលជិត១ខែ ដើម្បីប្រារព្ធទិវាអន្តរជាតិ ដើម្បីបញ្ចប់អំពើនិទ្ទណ្ឌភាពនៃបទឧក្រិដ្ឋលើអ្នកសារព័ត៌មាន ដោយចាប់ផ្ដើមពីថ្ងៃទី ២៩នេះ បន្តរហូតដល់ថ្ងៃទី២៦ ខែវិច្ឆិកា។ យុទ្ធនាការនេះមានគោលបំណងលើកកម្ពស់ការយល់

ដឹងពីតួនាទីអ្នកសារព័ត៌មានក្នុងសង្គមប្រជាធិបតេយ្យ និងអំពើនិទ្ទណ្ឌភាព ដែលកំពុងបន្តញាំញីក្នុងប្រទេសកម្ពុជា រួមទាំងឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មានផង។

សកម្មភាពក្នុងយុទ្ធនាការទាំងនោះ រួមមាន ការផ្សព្វផ្សាយឡើងវិញនូវវីដេអូរឿង «អ្នកបន្តវេន» រៀបរាប់ពីកូនប្រុសអ្នកសារព័ត៌មានម្នាក់ ដែលព្យាយាមស្វែងរកយុត្តិធម៌ជូនឪពុក ដែលត្រូវគេសម្លាប់ ការចេញផ្សាយវីដេអូប្រវត្តិអ្នកសារព័ត៌មាន ដែលត្រូវគេសម្លាប់ទាំង ១៥នាក់ ការផ្សាយផ្ទាល់កម្មវិធីវិទ្យុ និងវីដេអូស្ដីពីទិវាអន្តរជាតិដើម្បីបញ្ចប់និទ្ទណ្ឌភាព ព្រមទាំងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្ដីពីស្ថានភាពសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន សិទ្ធិទទួលព័ត៌មានសម្រាប់ឆ្នាំ២០២៤។

អង្គការសហប្រជាជាតិបានកំណត់យកថ្ងៃទី២ ខែវិច្ឆិកា ជាទិវាអន្តរជាតិ ដើម្បីបញ្ចប់និទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន៕